# អនុស្សរណៈនៃការយោគយល់គ្នា
# រវាង
# អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍
# និង
# ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា
# ស្តីពី
# ការចូលរួមសកម្មភាពមនុស្សធម៌ នៅព្រះរាជាណាចក្រកម្ពុជា

## ផ្នែកទី១
## បុព្វកថា

<u>ដោយហេតុថា:</u> ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា បានសំដែងនូវបំណងប្រាថ្នាចំពោះអង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ក្នុងការចូលរួមចំណែកធ្វើការងារមនុស្សធម៌ ក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីសុខុមាលភាពសង្គម និងប្រយោជន៍សាធារណៈតាមរយៈកិច្ចសហប្រតិបត្តិការគ្នាទៅវិញទៅមក ដូចមានចែងក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះ។

<u>ដោយហេតុថា:</u> អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ និងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវចូលរួមសហការក្នុងការប្រយុទ្ធប្រឆាំងនឹង*អំពើ*ជួញដូរមនុស្ស *អាជីវកម្មផ្លូវភេទ* និងការកេងប្រវ័ញ្ច*ពលកម្ម*លើស្ត្រី បុរស និង កុមារ។

<u>ដោយហេតុថា:</u> ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស *អាជីវកម្មផ្លូវភេទ* និងការកេងប្រវ័ញ្ច*ពលកម្ម*លើស្ត្រី បុរស និងកុមារ អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ និងក្រសួងមហាផ្ទៃតាមរយៈអគ្គស្នងការដ្ឋាននគរបាលជាតិ បានសហការយ៉ាងជោគជ័យជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងនាយកដ្ឋាន*នគរបាល*ព្រហ្មទណ្ឌ និងសំដែងនូវបំណងប្រាថ្នាក្នុងការបន្តកិច្ចសហការតាមរយៈសកម្មភាពមនុស្សធម៌ដូចខាងក្រោម:

<u>ការប្រមូល និងការផ្តល់ពត៌មានសម្ងាត់:</u>

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវសហការជាមួយនឹងអគ្គស្នងការដ្ឋាននគរបាលជាតិ ក្នុងការស៊ើបអង្កេត ប្រមូលភស្តុតាង និងពត៌មានសំខាន់ៗ អំពីសកម្មភាពនៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទលើ*ស្ត្រី បុរស* និងកុមារ *នៅតាម*បណ្តាទីតាំងដែលពាក់ព័ន្ធនឹងសកម្មភាព *អាជីវកម្មផ្លូវភេទ*

ដែលសង្ស័យថាមានស្ត្រី និងកុមារកំពុងត្រូវ បានជួញដូរ និង ឬត្រូវបានកេងប្រវ័ញ្ចផ្លូវភេទ។

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវធ្វើរបាយការណ៍ និងផ្តល់ភស្តុតាងលំអិត ដែលប្រមូលបានពីសកម្មភាពល្មើសពាក់ព័ន្ធនឹងការជួញដូរមនុស្ស *អាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកំលាំងពលកម្ម រំលោភសេពសន្ថវៈ* ការបៀតបៀនផ្លូវភេទ *និងអំពើហិង្សាក្នុងគ្រួសារ* រួចបញ្ជូនមកនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និង ឬនាយកដ្ឋាន*នគរបាលព្រហ្មទណ្ឌ*។

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវបន្តស្រាវជ្រាវ និងកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស *អាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចពលកម្ម*។

<u>ការធ្វើអន្តរាគមន៍ និងការសង្គ្រោះ</u>

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ សហការយ៉ាងជិតស្និទ្ធជាមួយនគរបាលជាតិកម្ពុជា *ដើម្បីសង្គ្រោះជនរងគ្រោះ*ដោយអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម *និងប្រមូលភស្តុតាង ព្រមទាំងធានាដល់ការចាប់* និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសឲ្យបានត្រឹមត្រូវតាមច្បាប់ *នៃព្រះ*រាជាណាចក្រកម្ពុជា *និងបញ្ជូនទៅតុលាការដើម្បីផ្តន្ទាទោសតាមច្បាប់*។

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវសហការជាមួយនគរបាលជាតិកម្ពុជា ជួយផ្តល់សេវាកម្មផ្នែកច្បាប់ដល់ជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ *និងការកេងប្រវ័ញ្ចលើកំលាំងពលកម្ម* ដើម្បីរកយុត្តិធម៌ជូនជនរងគ្រោះ ជាពិសេសអនីតិជន និងផ្តន្ទាទោសជនល្មើសទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

<u>ការសម្របសម្រួលក្រោយពេលសង្គ្រោះ</u>

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវសហការដើម្បីជួយដឹកជញ្ជូនជនរងគ្រោះចេញពីកន្លែងកើតហេតុទៅកាន់*ទីស្នាក់ការនគរបាលដើម្បីដំណើរការ* នៃការសម្ភាសន៍ ដែលធ្វើឡើងដោយនគរបាលមានសមត្ថកិច្ច និងដឹកជញ្ជូនជនរងគ្រោះពីស្នាក់ការនគរបាលទៅកាន់*មណ្ឌល*គាំពារជនរងគ្រោះ ដើម្បីថែទាំសុខភាព ព្រមទាំងជួយដឹកជញ្ជូនជនរងគ្រោះពីមណ្ឌលគាំពារទៅកាន់តុលាការដើម្បីចូលរួមនៅក្នុងនីតិវិធីរឿងក្តីតាមផ្លូវច្បាប់។

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ត្រូវសម្របសម្រួលជាមួយនគរបាលជាតិកម្ពុជា និងមន្ត្រីរាជរដ្ឋាភិបាលផ្សេងទៀត ក្នុងការរក្សាសម្ងាត់

*ជូនជនរងគ្រោះ* និងផ្តល់ការ*គាំពារ*ដោយយកចិត្តទុកដាក់ភ្លាមៗ *ជាពិសេសអនីតិជន* បន្ទាប់ពីការសង្គ្រោះ ។

ការបណ្តុះបណ្តាលនគរបាលកម្ពុជា:

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ *ត្រូវសហការផ្តល់*ការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជំនាញ *ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន និងនគរបាលព្រហ្មទណ្ឌ*នូវបច្ចេកទេសស៊ើបអង្កេត និងវិធានការការពារសហគមន៍ ដោយផ្អែកលើភាពចាំបាច់ និងតម្រូវការរបស់*ក្រសួងមហាផ្ទៃ*។

- អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌និងសង្គមអាស៊ីអាគ្នេយ៍បន្តរក្សានូវការប្តេជ្ញាចិត្តរបស់ខ្លួន*ក្នុងការ*គោរពតាមច្បាប់ និងបទបញ្ញត្តិផ្សេងៗ របស់ព្រះរាជាណាចក្រកម្ពុជា ព្រមទាំងពង្រឹងនូវកិច្ចសហប្រតិបត្តិការឲ្យកាន់តែជិតស្និទ្ធថែមទៀតជាមួយក្រសួងមហាផ្ទៃ ដើម្បីសម្រេចនូវគោលដៅមនុស្សធម៌រួម របស់ខ្លួន។

ក្រសួងមហាផ្ទៃ និងអង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ បានព្រមព្រៀងដូចខាងក្រោម:

## ផ្នែកទី ២
## ការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ
## ក្រសួងមហាផ្ទៃ ត្រូវទទួលខុសត្រូវដូចខាងក្រោម:

**មាត្រា ១** *ទទួលស្គាល់ពត៌មាន និងភស្តុតាងដែលប្រមូលបានទាក់ទងនឹងបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ច ពលកម្មលើបុរស ស្ត្រី និងកុមារ រំលោភសេពសន្ថវៈ បៀតបៀនផ្លូវភេទ និងអំពើហិង្សាក្នុងគ្រួសារ ក្នុងគោលបំណងប្រយុទ្ធប្រឆាំង និងទប់ស្កាត់អំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចលើពលកម្ម បុរស ស្ត្រី និងកុមារឲ្យមានប្រសិទ្ធភាពខ្ពស់។ សហការ និងចាត់វិធានការឲ្យទាន់ពេលវេលា ក្នុងការបង្ក្រាបបទល្មើសទាំងនេះ និងអន្តរាគមជួយសង្គ្រោះជនរងគ្រោះ។*

**មាត្រា ២** *អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវសហការជាមួយសមត្ថកិច្ចនគរបាលជាតិកម្ពុជា* ក្នុងការស៊ើបអង្កេត *និងប្រមូលភស្តុតាងនានា* ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស*នៅតាមផ្ទះបន* និងកន្លែងផ្សេងទៀតដែលបុរស *ស្ត្រី និង កុមារត្រូវបានគេជួញដូរ បង្ខាំងទុកធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចពលកម្ម។ ក្រោយប្រមូលបានភស្តុតាងស្របតាមនីតិវិធីច្បាប់ និងគ្រប់ជ្រុងជ្រោយអង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ត្រូវផ្តល់ភស្តុតាង*

ទាំងនោះទៅសមត្ថកិច្ចនគរបាលជាតិកម្ពុជា ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនជាបន្ទាន់ដើម្បីចាត់វិធានការតាមផ្លូវច្បាប់។ ក្នុងពេលប្រតិបត្តិការ ស៊ើបអង្កេត អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវសហការជាមួយកម្លាំងមានសមត្ថកិច្ច ដោយប្រកាន់ភ្ជាប់ទៅតាមអនុស្សរណៈនៃការយោគយល់គ្នានេះ។

**មាត្រា ៣**

ឧបករណ៍ដែលយកទៅប្រើប្រាស់ក្នុងការប្រមូលពត៌មាន និងភស្តុតាងពាក់ពន្ធ័អំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចពលកម្មលើបុរស ស្រ្តី និងកុមាររបស់អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ត្រូវមានការឯកភាពពីក្រសួងមហាផ្ទៃ។

**មាត្រា ៤**

មន្ត្រីនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងមន្ត្រីអង្គភាពគរបាលមានសមត្ថកិច្ចផ្សេងទៀត នឹងសហការជាមួយអង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ក្នុងការផ្លាស់ប្តូរព័ត៌មាន និងភស្តុតាងឲ្យគ្នាទៅវិញទៅមក ដើម្បីឈានទៅបង្ក្រាបបទល្មើស និងឃាត់ខ្លួនជនសង្ស័យឲ្យបានទាន់ពេលវេលា។

**មាត្រា ៥**

ក្នុងករណីចាំបាច់ និងមានតម្រូវការពីក្រសួងមហាផ្ទៃ អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ នឹងជួយបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងមន្ត្រីនគរបាលពាក់ព័ន្ធ។ កាសណ្តុះបណ្តាលរួមមានច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ បទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងរាល់ច្បាប់ដែលពាក់ព័ន្ធដ៏ទៃទៀត។

**មាត្រា ៦**

ក្រសួងមហាផ្ទៃ និងអង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ សហការរៀបចំគំរោងនានាក្នុងការជួយដល់សហគមន៍ និងជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកំលាំងពលកម្ម ព្រមទាំងជួយគាំទ្រដល់កិច្ចប្រតិបត្តិការរបស់នគរបាលនៅក្នុងរយៈពេល នៃការអនុវត្តគំរោងទាំងនោះ។

## ជំពូកទី ៣
## ភារកិច្ចរបស់ អង្គការស៊ើបអង្កេតសកម្មភាព មនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍
## (អង្គការស៊ីសា)
## អង្គការស៊ើបអង្កេតសកម្មភាព មនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ មានភារកិច្ចដូចខាងក្រោម៖

**មាត្រា ៧** អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ *ត្រូវ*គោរពច្បាប់ និងបទបញ្ញត្តិទាំងឡាយរបស់ព្រះរាជាណាចក្រកម្ពុជា និងមិនអនុញ្ញាតឲ្យភ្នាក់ងាររបស់ខ្លួនចូលរួម*ក្នុង*សកម្មភាពណាមួយ ដែលប៉ះពាល់ដល់សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម ឬសកម្មភាពដទៃទៀត ដែលអាចបង្កឲ្យអន្តរាយដល់សន្តិសុខជាតិ *ឯកភាពជាតិ*វប្បធម៌ និងប្រពៃណីរបស់ប្រជាជនកម្ពុជាឡើយ។

**មាត្រា ៨** អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ *ត្រូវអនុវត្តគំរោង និងកម្មវិធីមនុស្សធម៌*នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងក្របខ័ណ្ឌនៃធនធានបុគ្គលិក និងមូលនិធិរបស់ខ្លួន។ អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ នឹងធានាឲ្យបានថា រាល់*ការទទួលបាន*ភស្តុតាង *នៃការបំពាន*ច្បាប់កម្ពុជា ដែលខ្លួនបានប្រមូល *គឺត្រូវ*បញ្ជូនទៅអង្គភាពនគរបាលមានសមត្ថកិច្ចសម្រាប់ចាត់វិធានការបន្ត។ *រាល់ការចុះស៊ើបអង្កេត ត្រូវផ្តល់ព័ត៌មានមកអង្គភាពជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ រាល់នីតិវិធីនៃការស៊ើបអង្កេតសម្ងាត់ ត្រូវមានការពិភាក្សាឯកភាពរវាងភាគីទាំងពីរមុនពេលអនុវត្ត*។

**មាត្រា ៩** អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ នឹងចូលរួមតែសកម្មភាពមនុស្សធម៌ ដែលត្រូវបានអនុញ្ញាតដោយក្រសួងមហាផ្ទៃ នៃ*ព្រះរាជាណាចក្រកម្ពុជា* ដើម្បីសុខុមាលភាព និងផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះ និងជៀសវាងដាច់ខាត ពីការពាក់ព័ន្ធនឹងសកម្មភាពបង្កើតប្រាក់ចំណូល *ប្រាក់ចំណេញ* និងសកម្មភាពនយោបាយ ដែលមិនបំរើដល់គោលដៅមនុស្សធម៌។

## ជំពូកទី ៤
## អវសានបញ្ញត្តិ

**មាត្រា ១០** រាល់វិវាទរវាងក្រសួងមហាផ្ទៃ នៃ*ព្រះរាជាណាចក្រកម្ពុជា* និងអង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍ ដែលទាក់ទងនឹងការអនុវត្ត ឬការបកស្រាយអនុស្សរណៈ នឹងត្រូវបានដោះស្រាយតាមរយៈការចរចា ដោយសន្តិវិធីរវាងភាគីទាំងពីរ ។

**មាត្រា ១១** អនុស្សរណៈនៃការយោគយល់គ្នានេះ អាចត្រូវបញ្ចប់ដោយភាគីណាមួយក៏បាន គឺបន្ទាប់ពី៦០ថ្ងៃដែលភាគីនោះ ផ្តល់សេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរបញ្ជូនទៅភាគីម្ខាងទៀត។

**មាត្រា ១២** អនុស្សរណៈនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខា និងមានសុពលភាពរយៈពេល៣ឆ្នាំ *ហើយនឹងត្រូវបន្តសុពលភាព ដោយមានការព្រមព្រៀងរបស់ភាគីទាំងពីរ។*

**មាត្រា ១៣** អនុស្សរណៈនេះធ្វើឡើង*ជាពីរច្បាប់* ជាភាសាខ្មែរមួយច្បាប់ និងភាសាអង់គ្លេសមួយច្បាប់។
អត្ថបទទាំងពីរនេះ មានតំលៃស្មើគ្នា តាមផ្លូវ ច្បាប់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៧ ខែតុលា ឆ្នាំ២០១១

**ក្រសួងមហាផ្ទៃ**

**អង្គការស៊ើបអង្កេតសកម្មភាពមនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍**

**លោកជំទាវ ជូ ប៊ុនអេង**
**រដ្ឋលេខាធិការ**

**លោក** Steven John Morrish
**នាយកប្រតិបត្តិ អង្គការស៊ើបអង្កេតសកម្មភាព មនុស្សធម៌ និងសង្គមអាស៊ីអាគ្នេយ៍**